# អារម្ភកថា

ខ្លួនខ្ញុំនេះឯង មិនសូវចេះតែង ជាបទកំណាព្យ
តែខ្ញុំចូលចិត្ត រៀងរាបដរាប នូវបទកំណាព្យ
ដែលប្រាជ្ញតែងទុក។

ខ្ញុំសាកល្បងតែង កំណាព្យថ្វាថ្លៃង រឿងរ៉ាវអ្នកស្រុក
នៃជនជាតិខ្មែរ វេទនារងទុក្ខ ឃ្លាតឆ្ងាយពីសុខ
ច្រើនសតវត្សរ៍ហើយ។

ហេតុមកពីអ្វី បងប្អូនប្រុសស្រី កុំស្ងៀមកន្តើយ
ត្រូវជួយគិតគូរ រិះរកចម្លើយ បើឃើញផ្លូវហើយ
នាំគ្នាដើរទៅ ។

ខ្ញុំតែងបានខ្លះ ក្រែងលោមិនច្បាស់ អាចមានខុសត្រូវ
សូមអស់លោកអ្នក ជួយកែតម្រូវ គ្រាន់បានជាផ្លូវ
ជូនជាតិខេមរា ។

ខ្ញុំបោះពុម្ពផ្សាយ ជូនលោកទាំងឡាយ ជួយពិចារណា
នេះជាសំណៅ មិនមែនតម្រា ខុសត្រូវម្ដេចម្ដា
មេត្តាអភ័យ ។

ប្រសិនបើត្រូវ លោកអ្នកយកទៅ ខិតខំលកលៃ
នាំគ្នាបដិបត្តិ ឲ្យបានប្រពៃ ទុក្ខសោករោគភ័យ
នឹងអន្តរធាន ។

ក្ដីសុខចំរើន ទ្រព្យធនកើតកើន មង្គលកើតមាន
ជនជាតិកម្ពុជា បានសុខក្សេមក្សាន្ត រស់នៅថ្កើងថ្កាន
តអង្វែងទៅ ៕

ចាក ឈ្មោះគ្នាដល់ណា ឆ្នាំ ១៩៩៨

បើមិនចេះនាំ    កុំចង់ដើរមុខ
បើមិនចេះទំនុក    កុំចង់នាំគេរាំ